

សៀវភៅយើង
NOS LIVRES
OUR BOOKS

**© ឯម សត្យា**

និពន្ធ និងគំនូរ : **ឯម សត្យា** / រៀបចំ និងបោះពុម្ពផ្សាយ : **លឹម សន្តិភាព** និង **ចន វិតស៍**
ជំនួយការបោះពុម្ពផ្សាយ : **ស៊ឹម ស៊ីសាវុត្ថារ៉ា** / រចនាទំព័រ : **រស់ សុខជា** និង **សៅ ចាន់ណា**
ជំនួយការគំនូរ : **ម៉ើ ឱយ៉ាដារ៉ាវុធ**

សៀវភៅនេះទទួលបានការឧបត្ថម្ភពីស្ថានទូតបារាំងប្រចាំនៅកម្ពុជា
(កម្មវិធីជំនួយដល់ការបោះពុម្ពផ្សាយ **រឹម គិន** FSP VALEASE)

Ouvrage soutenu par l'Ambassade de France au Cambodge dans le cadre du Programme d'aide à la publication Rim Kin au titre du Fonds de solidarité prioritaire de Valorisation de l'Écrit en Asie du Sud-Est.

**អង្គការ សៀវភៅយើង**
ផ្ទះលេខ៦៧E១ ផ្លូវលេខ១៧៨ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ
ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៩៨៨
ទូរស័ព្ទ : 012 526 840 / 023 223 242
info@siewphewyeung.org.kh
http://www. siewphewyeung.org.kh

បោះពុម្ពនៅកម្ពុជាដោយរោងពុម្ព **គីម ឡុង**
ចែកចាយដោយ **Reading Books**
ទូរស័ព្ទ : 011 895 798 / 012 917 651 / 016 575 433

---

©2007-2008 រក្សាសិទ្ធិចំលង និងបកប្រែចំពោះគ្រប់ភាសាទាំងអស់ ដោយអង្គការ **សៀវភៅយើង**។
បុគ្គលណាថតចំលងដោយគ្មានការអនុញ្ញាតិពីអង្គការ **សៀវភៅយើង** បុគ្គលនោះនឹងត្រូវ
ទទួលទោសចំពោះមុខច្បាប់។

ក្រោមរស្មីព្រិចៗ នៃហ្វូងតារារាប់រយរាប់ពាន់ ទឹកស្ទឹងសង្កែនៅតែហូររិចៗ មិនចេះដាច់ ហាក់គ្មានក្ដីនឿយណាយនឹងធម្មជាតិដែលបានបង្កើតខ្លួនមកសោះឡើយ។ នៅមុខផ្ទះដំបូលស្បូវនាត្រើយខាងកើត គេឃើញមានពន្លឺភ្លើងចង្កៀងផ្លុងៗ...




អូហ៍! ក្មួយផល្លា និង ក្មួយហួចទេហ៍! មកចូលលេងសិនមក! កូនសុត្ថារវល់នៅឯស្ទឹងឯនុ៎! បន្តិចទៀតមកវិញហើយ...
តែអី...ខ្ញុំប្រញាប់! នៅយូរមិនបានទេ ចាំថ្ងៃក្រោយចុះអ្នកមីង!
កុំខ្មាស់អៀនអី! ក្មួយស្គាល់មីងយូរហើយ។ មកញ៉ាំនំអាកោលេងសិនទៅ! មីងទើបចំហុយឆ្អិនក្តៅៗ។


ចាស អ្នកមីង! អរគុណច្រើនណាស់។
ដើម្បីឆ្លើយតបទៅនឹងការគួរសមរបស់មីង កញ្ញាទាំងពីរក៏នៅអង្គុយលេងរង់ចាំសុត្ថា។ គាប់ជួនពេលនោះកូនចៅកែត្បូង ឈ្មោះដារីត និងមិត្តគេឈ្មោះរ៉ាឌីលេចមុខមកដល់ទីនេះដែរ ។
អស្ចារ្យ! អ្នកណាគេ អីក៏ស្អាតម្ល៉េះ ដារីត!
ផល្លាជាកូនលោកវីសុទ្ធ សេដ្ឋីស្រុកយើងណា៎! ឯងអត់ស្គាល់ទេហ្អ៎?


ភ្លាមនោះ ដារីតក៏ចុះមក
សំដែងការគួរសមរាក់
ទាក់ដាក់កញ្ញាយើង។
សួស្តី...ផល្លា
ហួច! មិននឹក
ស្មានថាសំណាង
បានជួបអ្នក
ទាំងពីរ
នៅទីនេះ
សោះ។
ស្រស់ស្រីផល្លាមិនសប្បាយចិត្តទេ
នៅពេលឃើញមុខដារីត និង រ៉ាឌី
ព្រោះគេជាយុវជនឱស្ក ដែលមាន
អាកប្បកិរិយាច្រឡឹមផុតលេខ...
មួយថ្ងៃៗ បើមិនបានត្រូវស្រីដេរ
មួយម៉ាត់ ពិតជាដេកមិនលក់
បក់មិនល្ហើយ បាយមិនឆ្ងាញ់
ទេមើលទៅ...។


អុីយ៉ា ផល្លាថ្ងៃនេះ ស្លៀកពាក់ស្អាត
ណាស់។ ធ្វើអោយខ្ញុំភ្លឹកស្មើរតែ
ភ្លេចដកដង្ហើមទៅហើយ។
នែ ដារីត!
កុំមកនិយាយ
លែបខាយ ផ្អែម
ល្ហែមអីនៅទី
នេះ នោះ។
ព្រឺសំបុរ
ណាស់។


ផល្លា ក្មួយចង់ទៅណា?
ចាស អ្នកមីង។
ខ្ញុំសុំទៅក្រោយមួយភ្លែតសិន!


ក្មួយប្រុសទាំងពីរសុខសប្បាយទេហ្អ៎? បាត់មុខ បាត់មាត់យូរ មិនដែលឃើញមកលេងសោះ។
ខ្ញុំសុខសប្បាយទេមីង។
ចំណែកខ្ញុំ ក៏អញ្ចឹងដែរ។
រំពេចនោះ មានរថយន្តមួយ មកដល់ស៊ីផ្លេ ទីន ទីន...
អីដារីត...វ៉ាឌី...មានម៉ូយថ្មីរ៉ឿយទៅហ្អ៎?
អញ្ជើញចុះក្មួយ។
ខ្ញុំជំរាបលាសិនហើយមីង។


ផល្លាគិតថា បើនឹងទៅផ្ទះវិញក្នុងពេលនេះ ច្បាស់ជាដារីត និងវ៉ាឪតាមញ៉ែរហូតដល់ផ្ទះមិនខាន ក៏ធ្វើជាសុំអ្នកមីងទៅក្រោយបន្តិចទុកអោយស្រីហួច និងមីងនៅកំដរភ្ញៀវមិនបានអញ្ជើញនេះ។ ស្រាប់តែជួបនឹងសុត្ថាមកពីកំពង់...
យី! អ្នកណា ដូចជាផល្លា!
ម៉េចក៏មកឈរអីម្នាក់ឯងទីនេះអញ្ចឹង?
ផល្លាអៀន មុខឡើងក្រហមព្រឿងៗ រកនឹកនិយាយឆ្លើយតបទៅវិញមិនឃើញ...


ផល្លាមានរឿងអ្វី ម្ដេចមិន
និយាយស្ដីអីសោះ?
មកពីសុភ្កាងគីហ្ស៊ី...ខ្ញុំចាំយូរពេក !...
ចាំខ្ញុំឬ ?
តើមានរឿងអ្វីទៅ !
សំដីកំបុត តែបាក់ផ្លូបផ្ដាំទន់ភ្លន់..
ផ្លូវផ្ដិតទោបក់មកញ្ញើយ ៗ.. ភ្លិន
ក្រអូបបានអើ្យហោយសុភ្កាមាន
អារម្មណ៍ក្តេបក្តាំមិនដឹង ៗ



កុំមាត់ព្ញពេក !..ដារីត និងរ៉ាឌី នៅខាងមុខណា៎...
សុត្ថាបន្ថយសំលេងនិយាយតិចៗ
តែ!ហេតុអ្វីក៏ផល្វា... ស្អប់គេម្ល៉េះ? មើលទៅ ដារីត គេដូចជាស្រ...
ទេ! បានហើយៗ... កុំចេះធ្វើមេអណ្ដើកអីនោះ! ប្រយ័ត្នខ្ញុំឈប់មករកសុត្ថា ឯងទៀតណា៎!
ព្ញដូច្នោះ សុត្ថាក៏ឈប់និយាយ... នាយអង្គុយស្ងៀមបាត់មាត់ឈឹង។
ខ្ញុំនិយាយលេងទេសុត្ថា!... ធ្វើម្ដេចខ្ញុំ នឹងឈប់មករកសុត្ថាបាន បើសុត្ថារៀនពូកែ ហើយបានប្រឡងជាប់ចូលរៀនថ្នាក់ឧត្តមសិក្សា ថ្នាក់ខ្ពស់ជាងខ្ញុំទៅទៀត...!


សុត្តាសម្លឹងមុខផល្លា
ជាថ្មីយ៉ាងយូរ ដោយ
ឃ្នាន់ខ្នាញ់នូវការ
ប៉ិនលើកដាក់
ពាក្យសំដីរបស់
នាង។ ជាការពិត
ណាស់ នាងនិងគេ
មានចិត្តដូចគ្នា គឺចង់
ក្លាយជាមិត្ត១០០ឆ្នាំនឹង
គ្នា តែសេចក្តីស្នេហាហាក់បីដូច
ជាបង្កប់យ៉ាងជ្រៅនៅក្នុងបេះដូង
របស់ពួកគេរៀងៗខ្លួន ពុំទាន់លេចជារូបរាងពិតប្រាកដនៅឡើយ។ នេះជាលើក
ទីមួយហើយ ដែលផល្លាប្រើពាក្យសំដីកោតសរសើរយុវជនយើង..។


សុត្តា! ដឹងទេថា ថ្ងៃនេះខ្ញុំចង់មកថ្លែងអំណរគុណចំពោះសុត្តា ដែលបានជួយបង្រៀនខ្ញុំរហូតដល់ខ្ញុំប្រលងជាប់បាក់ឌុបណោ៎!
អា៎! អស្ចារ្យ ផល្លាប្រលងជាប់ហើយ!


សុត្តារំភើបពេក ក៏ជ្រុលកាន់ដៃផល្លា ធ្វើអោយមុខនាងឡើងក្រហមព្រឿង។.....
អី! ផល្លាខឹងនឹងខ្ញុំ.. នែ៎... អម្បាញ់មិញ អត់ទោសផងចុះ ដោយខ្ញុំអរពេក បានជា...
ទេ! ខ្ញុំមិនប្រកាន់ទេ..
បើ...គ្មានទេ.. ហេតុអ្វីក៏មុខផល្លា..
អី...មើលទៅ ដូចជាយប់បន្តិចហើយ! នែ៎! នេះជាកាដូរបស់ខ្ញុំ សំរាប់អរគុណសុត្តា ថែរក្សាវាអោយបានល្អផង! ខ្ញុំគិតសុំលាទៅវិញសិនហើយ។ ពេលក្រោយចាំខ្ញុំមកលេងទៀត។


អរគុណណាស់ផល្លា! ខ្ញុំនិងថែរក្សា
វាអស់មួយជីវិតរបស់ខ្ញុំ។
អ៊ូ នោះគឺអាហួចទេតើ!
ខ្ញុំ ជំរាបលា
អ្នកមីងសិនហើយ។
មេឃចង់ភ្លៀងហើយ នេះយក
ក្រណាត់កៅស៊ូនេះជាប់ខ្លួនទៅ!


សុត្តាដើរកំដរផល្លា និងស្រីហួចទៅផ្ទះវិញ ព្រោះយប់ណាស់ហើយ។ បានពាក់កណ្តាលផ្លូវ ភ្លៀងធ្លាក់មកយ៉ាងខ្លាំង។ សំណាងល្អ សុត្តាបានយកក្រណាត់កៅស៊ូមកជាមួយ តែគេមិនទទួលទេ។ គេទុកអោយស្រស់ស្រីទាំងពីរទទួល។
ស្លាប់ហើយសុត្តា! អត់មានអ្វីទទូលទេ!... មិនកើតទេ ទទូលជាមួយពួកខ្ញុំមក! ទទឹកអស់ហើយ។
មែនហើយ
មិនបាច់ទេផល្លា ហួច!ខ្ញុំធ្លាប់អស់ទៅហើយ កុំបារម្ភអ្វី!
ហ៊ឺ!..បើកុំតែវ៉ាឪដារីតស្អីគេនោះ កុំអីក៏មិនបាច់អោយសុត្តាពិបាកដូច្នេះដែរ!
មិនអីទេ..ផល្លា! ហួច! នៅចាំអ្វីទៀត ប្រញាប់ចូលទៅក្នុងផ្ទះទៅ! រងាណាស់។
មើល! សុត្តាខំជូនយើងមកដល់ផ្ទះ ទទឹកជោគខ្លួន!


នារាត្រីភ្លៀងធ្លាក់នេះ ត្រលប់មកដល់ផ្ទះវិញ កំលោះសុត្ថាចេះតែនឹកឃើញដល់ស្នាមញញឹមដ៏សែនស្រស់គ្មានអ្វីប្រៀបបានរបស់កញ្ញាផល្លា។ ឱ ផល្លា! នាងជាបវរនារីឯក រស់ក្នុងត្រកូលអ្នកមានខ្ពស់ ប្រៀបបាននឹងដួងចន្ទ្រាដែលរះពេញបូរមីកណ្ដាលរាត្រី...
ទន្ទឹមនឹងនោះ មានហ្វូងតារាដេរដាស ពាសពេញផ្ទៃមេឃ ចោមរោមប្រណាំងប្រជែងដណ្ដើមគ្នាចង់នែបនិត្យនឹងដួងច័ន្ទរះមូលក្រឡង់មួយនេះ..។ តើសុត្ថាត្រូវធ្វើយ៉ាងណា ដើម្បីយកដៃដ៏ខ្លីនេះ ទៅឈោងចាប់យកចន្ទ្រាដ៏សែនខ្ពស់នោះបាន? យុវជនសុត្ថាមិនមានទ្រព្យ មានតែបេះដូងពិត។ កំលោះឪស្គូដារីត កូនអ្នកមានទ្រព្យមានបុណ្យស័ក្តិ។ តើកន្លង់ទាំងពីរ មួយណាទៅអាចទាក់ទាញចិត្តកុលាបស្រស់ស្អាតមួយនេះបាន?


ឱ! ជីវិតអើយ ហេតុអីក៏ពិបាកយល់ម៉្លេះ? បុប្ផក្រពុំលំអោនកាយមក ជិតនឹងដៃទៅហើយ ហេតុអ្វីបានជាមិនហ៊ានចាប់ នេះមកពីខ្ញុំកំសាក រឺមកពីខ្លួនខ្ញុំក្រពេក? ហ៊ឺ..បើតែយ៉ាងនេះ ពុំដឹងពេលណា ថ្ងៃណាទេ ទើបមានវាសនាអាច...
យី!ស្លាប់ហើយ.. ពុំដឹងជាអណ្តែតអណ្តូងដល់ណាទេ...


អេហ៏! សុត្ថា! ម៉េចដើរសឹងជាន់ខ្ញុំទៅហើយ ធ្វើជាមិនឃើញខ្ញុំទៀត... អាណិតដល់អ្នករៀនថ្នាក់ទាបជាងផង!...
អ៊ូ! ពុទ្ធោអើយ បើសិស្សរៀនថ្នាក់ទាបជាងស្អាតម្ល៉ឹងៗ កុំថាឡើយតែអ្នករៀនថ្នាក់ខ្ពស់ត្រឹមខ្ញុំ សូម្បីតែខ្ពស់ជាងខ្ញុំក៏ពុំហ៊ានដើរជាន់ដែរ...


បានហើយ! បានហើយ! កុំពូកែបញ្ឆោរ
ខ្ញុំពេក
គ្មានអ្វីឲ្យ
ទៀតទេ។
តែ...ផល្លាពិតជា
ចិត្តដាច់ដូចពាក្យនិយាយមែនឬ?

ណ្ហើយ!..ឥលូវកុំនិយាយច្រើនជូនខ្ញុំទៅផ្ទះ
ម៉ាក់យាយបន្តិចបានទេ?
អញ្ចឹង..ទៅក៏ទៅ។


ផ្ទះលោកយាយរបស់ផល្លានៅត្រើយខាងកើត ធ្វើពីឈើសង់ផ្ទាល់ដី។ ជួនជាចំថ្ងៃសីល គាត់ទៅវត្តបាត់តាំងពីព្រលឹម។
ធ្វើម៉េចទៅផល្លា បើគាត់មិនទៅអញ្ជើង។
យើងនៅលេង បន្តិចសិនទៅហ្អី!


អ្នកទាំងពីរឈរចាំមើលមួយស្របក់ ក៏នាំគ្នាដើរលេងក្នុងចំការ ដោយសេចក្តីរីករាយក្នុងចិត្ត...
យី! បងសុត្ថាទៅណាបាត់ទៅហើយ? កុំពួនណា៎! ប្រយ័ត្នខ្ញុំទៅផ្ទះចោល៎..!


យី ! បងសុត្តា យ៉ាងម៉េច អញ្ចឹង បងសុត្តា?
ការពិត សុត្តាត្រូវ ជំពប់ជើង នឹងឫសឈើ ដួលទៅលើវាលស្មៅ ។ ចៃដន្យ ផល្លា មកដល់ល្មម សុត្តាក៏ធ្វើជាពុំដឹងខ្លួនតែម្តង ។


ផល្លា! ឈប់សិនន៎! ខ្ញុំគ្មានកើតអីទេ ខ្ញុំមានរឿងមួយចង់និយាយប្រាប់ ផល្លាណា៎!
ទេ! ខ្ញុំមិនចង់ស្តាប់បងនិយាយទេ បងសុត្តាឯង ខូចណាស់ ធ្វើឲ្យខ្ញុំភ័យស្ទើរលស់ព្រលឹងទៅហើយ!


ផល្លា! ខ្ញុំមានរឿងមួយ និយាយ មែនណា៎...!
គ្មានអ្នកណាឃាត់មាត់ទេហ៎ ម្ដេចក៏មិននិយាយមក?
ប្រសិនបើខ្ញុំនិយាយទៅសមឬមិនគប្បីយ៉ាងណា ផល្លាកុំខឹងណា៎...! ខ្ញុំបានលួចស្រឡាញ់... ផល្លាយូរមកហើយ... ខ្ញុំនឹកស្រមៃឃើញតែផល្លាទាំងយប់ទាំងថ្ងៃ! តើផល្លាស្អប់ខ្ញុំទេ? ឬមួយក៏... ផល្លាមានគេប្រកាន់រួចទៅហើយ

លឺពាក្យសំដីរបស់សុត្ថាយ៉ាងនេះ ពុំដឹងឲ្យផល្លាគួរឆ្លើយយ៉ាងណាទេ នាងអៀនពេក ក៏ដើរចេញពីសុត្ថាមកកាន់ទោចក្រយាន្តវិញ។




ក្ដីសង្ឃឹមបានរសាត់ទៅឆ្ងាយ សែនឆ្ងាយពីសុត្ថា...ពេលនេះ គេប្រៀបបាននឹងគ្រឿងយន្ត គ្មានវិញ្ញាណដែលមាន ផល្លាជាអ្នកបញ្ជា។
តើរឿងខ្ញុំដូចពាក្យចាស់គេថាឬ? ខ្លួនទាបកុំតោង ដៃខ្លីកុំឈោង ស្រវាឱបភ្នំ។
បងសុត្ថា! យើងហួសផ្លូវឆ្លងស្ពានត្រលប់ទៅផ្ទះវិញហើយ រវល់តែគិតទៅណាហ្នឹង!
អា៎ ! អឺ មែន... មែនហើយ!..ខ្ញុំរវល់តែភ្លឹក... អត់ទោសផល្លា...


ភ្លាមនោះ ស្រាប់តែ
លេចអ្នកលេងពីរនាក់
ឈរស្កាត់ដំណើរ
អ្នកទាំងពីរ។
ឈប់សិន! អាសុត្ថា
ឯងគិតចង់ទៅណាហ៊្អាំ?
នរណា
គេទឹង?
សុត្ថា?
អាដេត
ឯងមកពី
ណា? ហេតុអី
បានជាមក
ឃាត់ផ្លូវ
យើង?


ម៉េចទៅឯងភ័យណាស់មែនទេ? ហ៊ិះ! អាសុត្ថា ឯងដូចជាសំងំស្ងុខពេកហើយ ពេលអញជាប់គុកឯងសប្បាយហ៊ឺហា ភ្លេចគ្រាកំសត់ជាមួយគ្នា! ឥឡូវបើឯងមិនចង់ឈឺសាច់ទេ ឆាប់ដកខ្លួនចេញពីស្រីស្រស់នេះ រួចយកម៉ូតូនោះភ្លាមទៅ...
ហ៊ិះ! អាដេត ហេតុអ្វីបានជាឯងមកបង្ករឿងជាមួយអញទៅវិញ អញខំជួយអប់រំឯង ឲ្យឯងដើរផ្លូវល្អ... តែឯងមានះដើរប្រព្រឹត្តអំពើអបាយមុខ រហូតវេទនាដោយខ្លួនឯង ឥឡូវឯងចង់មកសងគុណអញរបៀបនេះឬ?




អាផាន់ដើរមកជិត  រហ័សដូចព្រួញ វាក្ដួងសុត្ថាជាប់ រួចនិយាយគំរាមតិចៗ។






ព្រោះតែចារម្កពីសុវត្ថិភាពរបស់ផល្លា សុត្ថាក៏ព្រមស្តាប់តាមបញ្ជារបស់អាផាន់ ឡើងជិះម៉ូតូរបស់ផល្លា ហើយបើកចេញទៅជាមួយវា។ បានឆ្ងាយបន្តិច អាផាន់វាយសុត្ថាឲ្យសន្លប់ រួចអូសយកម៉ូតូ គេចខ្លួនបាត់ទៅ។ ចំណែកអាជេតវិញ វាចាប់ផល្លាអោយទៅឆ្ងាយពីសុត្ថា ហើយនិយាយថាសុត្ថាជាបក្សពួករបស់វាដែរ។




នាពេលនោះ ស្រាប់តែលេចមុខ ដារីត និង វ៉ាឌីចេញមកដែរ!
ឈប់សិន ហ្អែងចង់ធ្វើស្អីហ្អ៎ា? ឆាប់លែងផល្លាភ្លាមទៅ!
អា៎! ពុទ្ធោគីឡូ! ផល្លាទេតើ វីវរហើយ!
ដារីត ជួយខ្ញុំផង!
ហ៊ិុះ! ចំដាវំខានមែន!
ចាំមើល តើឯងខ្លាំងប៉ុណ្ណា បានហ៊ានមកអង្អែលពុកមាត់ខ្លាលេង ហាស់ ហាស់!


ពួកគេក៏ចាប់ផ្តើមឆាកប្រយុទ្ធភ្លាមមួយរំពេច។
មិនបានប៉ុន្មាន នាទីផង ដេត ត្រូវដារីតវាយ ត្រូវយ៉ាងដំណំ វិះតែនឹងបាក់ ធ្មេញអស់។




នៅពេលនគរបាលមកដល់ អាដេតក៏បានរត់គេចខ្លួនបាត់ទៅហើយ។




យី! ចុះលោកណាក៏គ្មាន សញ្ញាសោះអញ្ចឹង រថបើក ជុំបែងឯងអស់រលីង
អេប ៗ សូមអស់លោកមេត្តាអែបខាង ត្បិតអីប្រតិភូខ្ញុំប្រញាប់ខ្លាំងណាស់សូមជ្រាប ជាព័ត៌មានផងទាន!
ស្លាប់ ហើយបង ទំពែក ទេហ្អ៎!
យ៉ី! អាចង្រៃយក៏! ប៊ិះរបូតខោ លេចសាវម៉ាវដាក់គេ។
ដើ! អាសម្លាញ់យើងជាអ្នក នាំសារចិត្តល្អទេ គ្នាគ្មាន មនោសញ្ចេតនាលើឯងទេ ឆាប់ថយចេញទៅ!
វ៉ុស វ៉ុស!


អាក...អូយ គេចពី ជុំងមកលង់អន្ទាក់ គេចពីអ្នកមក ជួបនឹងនាង។
យី! អើ អាគាត់នេះស្មាន តែយើងជាសាច់ជ្រូកឬ? បាន ជាមកចង់ត្របាក់យើង ទាំងរស់អញ្ចឹង...
ចាច! ហក យកទៅ! អ្នកណាមិនស្គាល់ ខ្ទាប់ បាក់ឌុបខាងការ៉ាតេដូស្មោះ!
អឺក...អឺ ជួយផង ខ្ញុំមកនេះល្អជាទេ។ ខ្ញុំ គ្រាន់តែចង់មកសុំជួប លោកវីសុទ្ធបន្តិចទេតើ។
អ៊ូ! អ៊ីចឹងទេហ្អ៎! ស្មានតែ ចង់ចំណេញពីខ្ទាប់ខ្ញុំនេះ។ ចាំមួយភ្លែត ខ្ញុំទៅ អញ្ជើញលោកវីសុទ្ធមក។


យី អាប្រិុនេះលឿន នោះលឿន រកតែឯង ចូលមិនទាន់។
លោកៗៗ!!! វិសុទ្ធ...
មានការអីបានជាត្រហេបត្រហបម្ល៉េះ។
នាងផល្លា កំពុងតែមាន គ្រោះថ្នាក់។

បានដំណឹងភ្លាម លោកវិសុទ្ធម្នីម្នាជិះរថយន្តចេញភ្លែត។ តែនៅពេលលោកទៅដល់កន្លែងកើតហេតុ បាត់មនុស្សអស់រលីងទៅហើយ។ គឺពួកជនដៃដល់ទាំងពីរបានរត់គេចខ្លួនបាត់ ហើយក៏បាត់មិនឃើញសុគ្គាដែរ។ ឯផល្លាត្រូវក្រុមប៉ូលិសជួយធ្វើអន្តរាគមន៍ទាន់ពេល រួចក៏នាំដារីតមកព្យាបាលរបួសនៅឯមន្ទីរពេទ្យ ។




ផល្លានិយាយរឿងប្រាប់ទាំងទឹកភ្នែកដែលហូរធ្លាក់មក ខ្សោកៗ ដោយពុំដឹងខ្លួន។
ប៉ា ! កូនខុសហើយប៉ា... សូមប៉ាអត់ទោសឲ្យកូនផង...
ផល្លាកូន! កូនឈប់យំទៅ ប៉ាមិនបន្ទោសកូនទេ។ មនុស្សដូចអាសុត្ថានេះថ្ងៃក្រោយ កូនឈប់ទាក់ទងនឹងវាទៅ ប្រយ័ត្នវានាំគ្នាវាមកធ្វើបាបកូនទៀត។


ជាមួយគ្នានោះ ទ្វារពេទ្យបើកឡើង គឺជាប៉ាម៉ាក់របស់ដារីត...
អា៎ ! សួស្តីលោកវីសុទ្ធ!
បាទ...បាទ សួស្តី លោកថៅកែស៊ុន... ខ្ញុំអរគុណលោក និងកូនលោកខ្លាំងណាស់ ដែលបានជួយកូនស្រីខ្ញុំ តើដារីតយ៉ាងម៉េចទៅហើយលោក?


ចាស៎ ! មិនអីទេចា៎ ! លោកវេជ្ជបណ្ឌិតថា ទាល់តែមានការថែទាំឲ្យបានជិតដល់ ទើបសរសៃក្បាលដែលត្រូវរបួសនោះ នឹងជាសះស្បើយជាធម្មតាឡើយវិញ។
ពិតមែនហើយលោកវិសុទ្ធ! បើនិយាយពីលុយកាក់ ប្រាក់កាស វាជារឿងធម្មតាទេ តែវាទាស់តែរឿងផ្លូវចិត្ត ខ្ញុំពិបាកគិតណាស់។ ឥឡូវវាពុំដឹងខ្លួនសោះ វារវើរវាយរកតែផល្លា កូនលោកហ្នឹង !
ហ៊ឺ ! សូមលោកកុំពិបាកចិត្តអ្វី  កូនខ្ញុំ និងខ្ញុំនឹងធ្វើគ្រប់យ៉ាងដើម្បីសងគុណជារីតវិញ។


ក្នុងសភាពបែបនេះ ផល្លាយល់ច្បាស់ណាស់ពីសន្ដានចិត្តរបស់ប៉ានាង។ នាងគេងគិតខ្វាយខ្វល់ក្នុងចិត្តតែម្នាក់ឯងថា:
ឱ! ស្នេហា ហេតុអ្វីក៏អ្នកធ្វើឲ្យខ្ញុំពិបាកចិត្តខ្លាំងម្ល៉េះ! យុវជនម្នាក់ដែលខ្ញុំស្អប់ខ្ពើមបំផុត ឥឡូវប្រែជាអ្នកជួយយកអាសារខ្ញុំ មិនគិតពីជីវិតខ្លួនទៅវិញ... រីឯសុត្ថាដែលភ្នែកខ្ញុំ ចិត្តខ្ញុំធ្លាប់សង្ឃឹមទុកថាគេជាម្ចាស់បេះដូងនៃជីវិតរបស់ខ្ញុំ ប្រែជាមនុស្សគួរឲ្យភ័យខ្លាចសេពគប់នឹងជនពាល។


ផល្លាកូនប៉ា! កូនមិនបាច់គិតច្រើនពីសុត្ថាទៀតទេ រឿងនេះ បើកុំតែប៉ាយល់ថា សុត្ថាធ្លាប់មានទំនាក់ទំនងល្អ នឹងគ្រួសារយើងពីមុនមក កុំអីប៉ាមិនអត់អោនឲ្យគេទេ... នេះវាសមមិនខុសនឹងពាក្យចាស់ពោលថា ឈើកោងវល្លិពន្ធ័ មនុស្សខ្នាត់ព្រាត់កុំយកខ្លួនបៀត។
ប៉ា ! កូនឈប់ចង់ដឹងពីរឿងនោះទៀតហើយ។ ប៉ាកុំខ្វល់អី!
ល្អហើយកូនប៉ា! កូនត្រូវឧស្សាហ៍ទៅមើលដារីតឯមន្ទីរពេទ្យផងណា៎! ប៉ាទៅធ្វើការហើយ។


រាត្រីសម្ងាត់បានរសាត់តាមវាយោ ហូរដូចជលសាកន្លងផុតទៅ...។ ផល្លាបានមកលេងគេហដ្ឋានដារីតដូចសព្វដង។
ផល្លា... ខ្ញុំអរគុណណាស់ ដោយបានផល្លាមកសួរសុខទុក្ខខ្ញុំជារៀងរាល់ថ្ងៃ រហូតធ្វើឲ្យជំងឺខ្ញុំធាប់ជា... ហើយក៏រឹតតែធ្វើឲ្យខ្ញុំស្រឡាញ់ផល្លាកាន់តែខ្លាំងឡើង។
ខ្ញុំប្រហែលជាមិនសាកសមនឹងផល្លាទេដឹង? តែបើដូច្នោះមែន ខ្ញុំពិតជារស់គ្មានន័យអស់មួយជីវិត...
ទេ...ឈប់ពោលយ៉ាងនេះទៀតទៅ... ដារីត ខ្ញុំមិនស្អប់អ្នកទេ សូមអ្នកឈប់អស់សង្ឃឹមទៀតទៅ!


បើដូច្នោះមែន ខ្ញុំមានសេចក្ដីត្រេកអរណាស់! ខ្ញុំសន្យាចំពោះមុខផល្លាថា ខ្ញុំមិនធ្វើដូចមុនទៀតឡើយ!.. អ្វីៗ ដែលផល្លាស្រឡាញ់ពេញចិត្ត ខ្ញុំនឹងបំពេញបំណងផល្លាទាំងអស់។
បានហើយ!.. បានហើយ... ថ្ងៃនេះ ខ្ញុំរកបងជូនខ្ញុំទៅផ្សារ ទិញរបស់របរមួយចំនួន សំរាប់ថ្ងៃធ្វើពិធីបុណ្យ កំណើតខ្ញុំណា៎!
ដោយរីករាយ!...




ដារីតតែងមកជួបនឹងផល្លាជាញឹកញាប់ដើម្បីប្រលោមលួងស្នេហ៍របស់គេ
ឲ្យកាន់តែជ្រួតជ្រាបទៅក្នុងក្រអៅបេះដូងដ៏បរិសុទ្ធរបស់ផល្លា។ តើមាន
អ្វីជាបញ្ហាទៀតបើគេទាំងពីរសុទ្ធតែរស់នៅក្នុងត្រកូលអ្នកខ្ពង់ខ្ពស់ដូចគ្នា?


គួរឲ្យពិបាកយល់មែន ជម្ងឺរបស់ដាវីតជាជម្ងឺសតិអារម្មណ៍ គេត្រូវការសប្បាយ សប្បាយដូចជាប៉ាម៉ាក់គេថាមែន ..។ ថ្ងៃនេះគេបានត្រលប់មកផ្ទះវិញ ដើម្បីធ្វើពិធីឧបកិច្ចយ៉ាងទំនើបដើម្បីលាងជំរះនូវគ្រោះចង្រៃ រង់ចាំទទួលនូវជ័យជំនះថ្មីរបស់គេ...។
អស្ចារ្យអាផាន់ អាជេត ឯងធ្វើបានល្អមែន!
នេះហើយ គេថាបាញ់មួយគ្រាប់ ជាប់សត្វពីរណា ចៅហ្វាយ។


ហាស់ ហាស់សប្បាយមែន! សប្បាយមែន! មានលុយមានអ្វីៗទាំងអស់ ស្អែកនេះនាងនឹងឆ្លើយនឹងសំនួររបស់ខ្ញុំ... ផល្លា... ផល្លាស្នេហាបង !
ស្លាប់ហើយ...រវល់តែរឿងផល្លា ចុះផល្លីឯណោះវិញ បងមិនគិតទេហ្អ៎?
ម្ដេចក៏និយាយអញ្ចឹង ព្រលឹងមាសបង !...


រាត្រីកាលបានកន្លងផុតទៅ...ព្រះអាទិត្យបានរះជាថ្មីនៅទិសបូព៌ា។ សុត្ថាភ្ញាក់ឡើងរសេះរសោះអស់ខ្លួនប្រាណ ឯក្បាលរបស់គេក៏ហាក់ទទួលការឈឺចាប់ខ្ទោក ៗដែរ។
អឺះ...យី..ហួចទេ!.. ហេតុអ្វីក៏ខ្ញុំមកនៅទីនេះទៅវិញ! តើទីនេះជាកន្លែងណាទៅ?
បងសុត្ថា! ទីនេះជាផ្ទះរបស់ខ្ញុំ ហើយតើ.. កុំបារម្ភអ្វី..
ហួច ជួយប្រាប់ខ្ញុំផង តើរឿងពីយប់មិញយ៉ាងដូចម្ដេចខ្លះ?
ហ៊ឺ... ពីយប់មិញ ពូខ្ញុំឃើញបងពុំស្រួល។ គាត់បានដើរទៅតាមក្រោយ ហើយឃើញបងដេកដួលនៅក្បាលស្ពានថ្ម។ គាត់ក៏គ្រាបងដាក់រ៉ឺម៉កមកនេះតែម្ដងទៅ។


មិនតែប៉ុណ្ណោះ គាត់បានទៅរកម្តាយបង ដល់ផ្ទះទាំងយប់ទៀត តែគ្មានអ្នកណា នៅសោះ!..
ពិតមែនហើយ គាត់មិននៅ ផ្ទះទេហួច! គាត់បានទៅជួយការ គេជិតនោះ បើសិនជាគាត់ដឹង គាត់ពុំដឹងជាពិបាកចិត្តយ៉ាងណា ទេ.. ខ្ញុំអគុណហួចច្រើនណាស់!.. ពុំគួរណាធ្វើអោយហួចពិបាក ដូច្នេះសោះ! ខ្ញុំជាមនុស្សគួរ អោយស្អប់ខ្ពើមណាស់។
ការជួយគ្នាទៅវិញទៅមកជាភារកិច្ចរបស់ យើងគ្រប់ៗគ្នា។ តែសូមបងសុត្ថាអាណិត ម្តាយដែលចាស់ជរាខ្លះផង...កុំបណ្តែត បណ្តោយខ្លួនតាមយថាកម្មខ្លាំងពេក.. បបរនេះសូមបងពិសា ទៅណា៎..
ហួច ប្រហែល ជានាងគិតថាខ្ញុំជា មនុស្សបែបនេះ ហើយមើលទៅ។


រួចហើយ ហួចក៏ចេញទៅធ្វើការដូចសព្វដង។ លុះត្រលប់មកវិញ នាង ពុំឃើញសុត្តាសោះ...
ចាស ទេពូ ខ្ញុំគ្មានរឿងអ្វី ជាមួយនឹងគាត់ទេ។
ហួចក្មួយ! ក្មួយមានរឿងអ្វី ជាមួយសុត្តាទេដឹង?
ប្រហែលហើយពូ ព្រោះគាត់ ដូចជាគ្រាន់បើហើយ មុនពេល ខ្ញុំទៅធ្វើការនោះ។
ប្រហែលជាគេត្រលប់ទៅ ផ្ទះវិញហើយទេដឹង។

និយាយពីសុត្ថា ក្រោយពីឧបត្តិហេតុនោះកើតឡើង គេក៏ត្រូវរងគ្រោះដោយពួកចោរពាលវាយសន្លប់បាត់ស្មារតី រួចយកទោចក្រយាន្តចេញទៅ ។ លុះពេលគេដឹងខ្លួនឡើង អ្វីៗបានកន្លងទៅយ៉ាងឈឺចាប់ខ្លោចផ្សាបំផុត គឺពុំមែនត្រឹមតែខ្លួនត្រូវរបួសប៉ុណ្ណោះទេ កិត្តិយសត្រូវស្អុយអាក្រក់ ហើយឪពុកនាងផល្លាបានមកតិះដៀល និងហាមប្រាមយ៉ាងតឹងរឹងឈប់ឲ្យនាយទៅមានទំនាក់ទំនងអីទឹងផល្លាតទៅមុខទៀត...



ស្ថិតក្នុងសភាពអស់សង្ឃឹម សុត្ថាលួចតូចចិត្តនឹងខ្លួនឯងដែលកើតមកជាកូនអ្នកក្រ ទើបបានជាឪពុកផល្លាមិនព្រមស្តាប់ការពន្យល់បកស្រាយរបស់នាយ។ ថ្ងៃណាក៏គេនឹកដល់ផល្លា គេចង់មករកផល្លា តែគេមិនហ៊ាន។ នៅពេលទំនេរ គេក៏ធ្វើជាកម្មករធាក់ស៊ីក្លូដើម្បីរកប្រាក់ចំណូលបន្ថែម...។




ធាក់ស៊ីក្លូបណ្ដើរ ភ្នែកសំឡឹងរកមើលផល្លា បណ្ដើរ ស្រាប់តែមកប៉ះនឹងឡាននាងតែម្ដង។
អេ! ពូស៊ីក្លូមិនមើលមុខមើល ក្រោយទេហ្អ? បានជាមកប៉ះរថយន្តខ្ញុំដូច្នេះ?
ដល់អញ្ចឹង
សុត្ថាភ័យបែកញើសប៉ុនៗគ្រាប់ពោត។
ទៅ លាក់មុខ ឲ្យខ្ញៅ.... ថ្ងៃក្រោយ ប្រយ័ត្ន ណា៎!
នេះបានចំជាខ្លួន ក្រមិនដឹងខ្លួនក្រមែន បើ កុំតែថ្ងៃបុណ្យទេហ្អា កុំអី យើងមិនយល់មុខ សោះឡើយ។
អឺ.បាទ...បាទសូមតែ លោក និង អ្នកស្រីអត់ទោស ផងចុះ ខ្ញុំគ្មានចេតនាទេទាន...


មិននឹកស្មានសោះថាថ្ងៃដែលគេមករកនាង ប្រែជាថ្ងៃដែលគេត្រូវទទួលការស្តីបន្ទោសពីនាងទៅវិញ។ នេះហើយឬ កុលាបតែងមានបន្លា ស្នេហាតែងមានឧបសគ្គ។ ទឹកចិត្តចុះចាញ់ទឹកប្រាក់។ វណ្ណៈត្របាក់ស្នេហ៍ខ្ញុំ...។
ឱ ផល្លា! អ្នកបានសេចក្តីសុខណាស់។ អ្នកពិតជាភ្លេចខ្ញុំហើយ។ ហេតុនេះហើយ បានជាអ្នកមិនឆ្លើយនឹងសំនួររបស់ខ្ញុំ...
គួរឲ្យស្តាយណាស់ កើតមកក្នុងជាតិនេះ...
អាំ! ក្មួយសុត្ថា យូរៗបានជួបពូម្តង កុំប្រកែប្រកាន់អី! ពិសាទៅៗ ពូមិនគិតលុយ គិតកាក់អីទេ! រឿងឯងពូដឹងហើយ។ ឯងពិតជាពិបាកចិត្តដោះស្រាយមិនចេញ! ណ្ហើយ! ឥឡូវដាក់មួយពែងទៅដាក់ទៅ! បើមិនអញ្ជឹងទេក្មួយមិនស្រឡាញ់ពូទេ។
តែ! ពូ...ខ្ញុំ... ខ្ញុំមិនចេះទេពូ ហើយដូចជាមិនស្រួលខ្លួនផង។

ដោយការបង្ខំរបស់ពូ សុត្ថាក៏ជ្រុលផឹករហូតភ្លេចខ្លួន។ បំរុងនឹងលាត្រឡប់មក ផ្ទះវិញ...ស្រាប់តែមកប្រទះនឹងផល្លា និងអាហ្វូចចុះពីរថយន្តជាថ្មីម្តងទៀត។




យ៉ាំងម៉េចសុត្ថា រអៀសខ្លួនណាស់ឬ? សុត្ថានៅតែចង់បំភាន់ភ្នែកខ្ញុំ ដើម្បី រំលែកនូវកិត្តិយស និងទ្រព្យសម្បត្តិរបស់ខ្ញុំឬ? តាមពិតខ្ញុំចំណាំរូបរាង សុត្ថាច្បាស់ណាស់។ សុត្ថាជាកម្មករស៊ីក្លូ តែខ្ញុំយល់មុខ ខ្ញុំអាណិតទុកមុខ ឲ្យអ្នកជានិសិត្សឧត្តមសិក្សាម្នាក់ តែសុត្ថានៅតែមិនយល់...! ខ្ញុំមកនេះ ដើម្បីជួបសុត្ថា ឲ្យភ្នែកខ្ញុំបានឃើញច្បាស់ ឈប់ប្រឡំទៀត!... ឥឡូវវាពិត ហើយ ស្តាយណាស់មិនគួរណាអ្នកចេះដឹងដូចសុត្ថា ជាមនុស្សចូលចិត្តផឹក ស្រាអាវាសែសោះ...


ស្តាប់ខ្ញុំនិយាយសិន រឿងនេះ វាវែងឆ្ងាយណាស់ផល្លា។
បានហើយ...ខ្ញុំជឿហើយ... ខ្ញុំឃើញច្បាស់នឹងភ្នែកហើយ!...
ផល្លាបញ្ឈាររថយន្ត
ចេញទៅទាំងក្តីឈឺផ្សាក្នុងចិត្ត។




គេបានសំឡឹងឃើញយ៉ាងច្បាស់នូវទឹកភ្នែកពីរតំណក់របស់នាង...ផល្លា...
នាងពិតជាស្អប់គេហើយ... នាងពិតជាឈប់វិលត្រឡប់មករកគេទៀតហើយ...
តើមានអ្វីទៅដែលអាចជួយគេបាន...?
ឱ! ស្ទឹងសង្កែ មានតែអ្នកទេដែលដឹងរឿងពិតខ្ញុំ សូមអ្នកជួយហូរទៅប្រាប់នាងផង
ថាខ្ញុំស្រលាញ់នាងដោយស្មោះ... ប៉ុន្តែធ្វើម្តេចបើជីវិតខ្ញុំបែបនេះ...


សុត្ថាបានចាកចេញពីផ្ទះហួច ត្រលប់មកផ្ទះរបស់ខ្លួនវិញ។ សុត្ថាចាប់ផ្តើមពិចារណានឹកអាណិតដល់ម្តាយរបស់ខ្លួន គេក៏តាំងចិត្តងើបឡើងតស៊ូនឹងជីវិតនេះតទៅទៀត។ ក្រោយពេលបញ្ចប់ការសិក្សា...
ម៉ែ... ខ្ញុំគិតទៅភ្នំពេញ រកការងារធ្វើ តើម៉ែយល់យ៉ាងណាដែរ?
តាមតែកូនគិតទៅចុះ។
បានការអនុញ្ញាតិពីម្តាយភ្លាម សុត្ថាប្រញាប់រៀបចំអីវ៉ាន់របស់ខ្លួនភ្លាមដែរ។

ក្រោមផ្ទៃមេឃដ៏ធំល្វឹងល្វើយ ខ្សែរថភ្លើងមួយបានបោលក្នុងល្បឿនមធ្យម ពីបាត់ដំបង មកភ្នំពេញ ក្នុងចំណោមអ្នកដំណើរជាច្រើនដែលជជែកគ្នារអេករអូច ពីនេះពីនោះមិនចេះដាច់ សុត្ថាអង្គុយត្រម៉ង់ត្រមោចម្នាក់ឯងក្បែរមាត់បង្អួចនៃទូរទេះភ្លើង។ អារម្មណ៍របស់គេតែងនឹកស្រមៃជានិច្ចដល់ផល្លាដែលគេកំពុងឃ្លាតឆ្ងាយបន្តិចម្តងៗ ហាក់ពុំដឹងថា មានថ្ងៃណានឹងអាចវិលត្រឡប់មកវិញបាន។ ជាពិសេសទៅទៀត នៅពេលដែលគេឡើងរថភ្លើង ម្តាយរបស់គេលើកដៃលាទាំងទឹកមុខស្រពោន ដែលតាំងពីកើតមកគេពុំដែលឃើញសោះនូវសភាពបែបនេះ ។



ភ្នំពេញមានសភាពអ៊ូអរមិនដាច់សូរ។ ដោយឡែកនៅសម្លេងកណ្ដឹងនៃដំបូលព្រះវិហារក្លីងក្លង់។ គួរអោយស្រណោះ។ សុគ្គាពុំមានស្គាល់អ្នកណាទាំងអស់ ក្រៅពីតេជគុណមាស។ សំណាងល្អ តេជគុណបានអោយគេស្នាក់នៅ និងព្រមទាំងជួយទំនុកបំរុងរកការងារអោយធ្វើទៀតផង។




ថ្ងៃនេះថៅកែសាន គេនិមន្តអាត្មា ទៅធ្វើសង្ឃទាននៅផ្ទះរបស់គេ.. គេមានណាស់ ហើយគេចូលចិត្តធ្វើបុណ្យទៀតផង! ប៉ុន្មានខែនេះឮថា ក្រុមហ៊ុនថតថាសចំរៀងរបស់គេត្រូវជ្រើសរើសបុគ្គលិក ចូលបន្ថែម! ចាំមើលតាសួរគេមើល៍ ក្រែងចៅ អាចចូលធ្វើការបាននឹងគេ..
លោកតា..នោះរថយន្តគេ មកដល់ហើយ លោកតា..

រថយន្តទំនើបបានបើកចេញទៅបាត់ស្រមោល..។ ដំណឹងល្អបានមកដល់ ក្រោយពីតេជគុណមាសត្រឡប់មកពីសង្ឃទានវិញ។ គឺសុត្ថាត្រូវបាន ការងារធ្វើនៅក្នុងក្រុមហ៊ុនថ្មីរបស់ថៅសានពិតប្រាកដមែន។ សុត្ថា សប្បាយចិត្តណាស់ចំពោះការងាររបស់គេ គឺមិនគ្រាន់តែជាអ្នកនិពន្ធ ប៉ុណ្ណោះទេ ថែមទាំងជាអ្នកចំរៀងដែលមានសំលេងក្រអួនពិរោះទៀតផង....




ណោះ! សូមអញ្ជើញមើលខ្លួនឯងទៅ!
ស្តាយដែរ.. បើដឹងថាអ្នកចំរៀងជាលោកវិញ
តែស្រមោលមិនចង់ឃើញផង!..
ខ្ញុំលាសិនហើយ!..


អត់ទោស!
ឈប់សិនអ្នកនាង សូម
កុំអាលប្រញាប់ពេក!
អ្នកនាងច្រឡំហើយ
សំបុត្រនេះពុំមែនរបស់
ខ្ញុំទេបាទ!...


ហ៊ឺស.. អី គឺមិនមែនអ្នកឯងទេឬ?
អឺះ..នែ៎! អត់ទេបាទ! ខ្ញុំហ្នឹងមែនហើយ! តែខ្ញុំគ្រាន់តែចង់ឲ្យអ្នកនាងមើលខ្ញុំអោយច្បាស់ កុំអោយថ្ងៃក្រោយច្រឡំទេតើ!
ហឺស ខ្ញុំស្អប់អ្នកឯងណាស់ ចាំមើលខ្ញុំប្រាប់ប៉ាខ្ញុំហើយ!
លិខិតអញ្ជើញទៅថ្ងៃនេះជាប្រញាប់ ហត្ថលេខាសាន់... ហ៊ឺ! មានរឿងអី
អញ្ចេះ! លឿននេះលឿនដូចអាមិច រកតែសួរអ្វីមិនទាន់..
នេះបានចំជាកូន ចៅកែមែន!


គេហដ្ឋានថៅកែសាន
អេ! ប៉ា ប៉ា ប៉ាមើលអីហ្នឹង បានជារអ៊ូម្នាក់ឯងទៀតហើយ
អូហ៍! ប៉ាមានសេចក្តីសប្បាយចិត្តណាស់! ព្រោះគេកំពុងជួយអោយក្រុមហ៊ុនយើងល្បីខ្លាំងឡើងៗ ហើយទទួលបានប្រាក់ចំណេញច្រើនទៀតផង! កូនមិនដឹងទេហ៎!
អូហ៎! តាមពិតគឺសុគ្គាអីគេហ្នឹងទៀតហើយ អោយខ្ញុំសុំយកទៅមើលមួយភ្លែតសិតណាប៉ា
យី! ចុះហេតុយ៉ាងដូចម្តេចក៏កូនចាំបាច់យកទៅធ្វើអ្វីណ៎?


ខណៈនោះ កវីសុត្តាក៏មកដល់....


អង្គុយចុះមកសុត្ថា កូនខ្ញុំនេះវាលេងច្រើនបន្តិចហើយ សូមមេត្តាកុំប្រកាន់អី។
បាទលោក ការពិតវីតតែធ្វើអោយខ្ញុំសប្បាយចិត្តទៅវិញទេ ព្រោះខ្ញុំកំព្រាតាំងពីតូចមក បើបាននាងតូចចូលចិត្តខ្ញុំ គឺជាសំណាងរបស់ខ្ញុំទៅហើយ
ហឺស! ស្អប់ណាស់។
នែ៎! ខ្ញុំហៅឯងមកនេះគឺចង់ប្រាប់រឿងមួយ ក្រោយពីយើងថតបញ្ចូលទៅក្នុងកម្មវិធីទូរទស្សន៍ចប់ យើងនឹងបានឈប់សំរាកមួយខែ។ ហើយក្រុមហ៊ុនក៏សំរេចទិញរថយន្តមួយអោយឯងដែរ...


ហឹស បើអញ្ចឹងវិញ
ញញឹមអោយខ្ចឹប!
ស្អប់ណាស់។


គ្មានផ្លូវទេ។
តែប្រយត្ន៍ស្អប់
ជំពប់លើណា! និយាយដូច
ប៉ាលីនទើបត្រូវណាំ...


អាលីនទ្រាំមិនបាន ក៏ហក់ទៅច្រានសុត្ថា សំណាងល្អដែលសុត្ថាប្រុងខ្លួនជាស្រេច ទើបគេមិនដួល។
អ៊ីយ៉ា អាលីនលេងបែបនេះ គួរអោយស្រលាញ់ណាស់!
អ្នកឯងនេះចំជា មុខក្រាស់មែនហើយ។


នាងកញ្ញាតូចច្រឡឹង ខឹងខ្ទាញ់សុត្ថាណាស់ នាងត្រឡប់មកវិញទាំងក្តីហួងហែង។
ពេលនោះ មិត្តភក្តិដែលមកលេងនាង ក៏ស្ទុះមកដណ្តឹងសួរនាងគ្រប់គ្នា..។
គេជាសុត្ថា អ្នកចំរៀងដ៏ល្បីនោះ មែនទេ?
មែនហើយ ខ្ញុំឃើញគេឧស្សាហ៍ចេញនៅតាមទូរទស្សន៍ណាស់។

នៅឯបាត់ដំបងឯណោះវិញ ផល្លាអង្គុយចាក់ស្រោមខ្នើយសំរាប់ថ្ងៃ អាពាហ៍ពិពាហ៍របស់នាង។ ឪពុករបស់នាងឃើញយប់កាន់តែជ្រៅ ហើយក៏ចូលមកសួរនាង។




ប៉ាលេបហើយ។ កូនជិតរៀបការ
ហើយ។ ប៉ាសប្បាយចិត្តណាស់។
ពេលខ្ញុំរៀបការរួច
ខ្ញុំចង់នៅខាងយើង តែដារីតគេចង់នៅខាង
គេ។ ខ្ញុំមិនដឹងគិតយ៉ាងម៉េចទេ?
មិនអីទេ។ រឿងនេះ ចាំនិយាយ
ពេលក្រោយទៅចុះ។ ប៉ាចូលគេងមុន
ហើយណ៎ា។
ចាស អញ្ជើញចុះលោកប៉ា។

នៅពេលឪពុកផល្លាចូលទៅបន្ទប់របស់ខ្លួន ទូរទស្សន៍បានហៅឈ្មោះ សុត្តា តារាចំរៀងប្រជាប្រិយ។ គ្រាន់តែលឺឈ្មោះនេះភ្លាម ផល្លាភ្ញាក់ព្រើត។ ពេលនោះ នាងផ្តោតអារម្មណ៍ទៅតាមបទចំរៀងរបស់សុត្តា ដែលច្រៀងរៀបរាប់ពីស្នេហាភក្តីរបស់គេជាមួយនឹងកុលាបនៅបាត់ដំបង។ ផល្លានឹកឃើញរាល់អនុស្សាវរីយ៍របស់នាង និងសុត្តា។



ទោះជាពេលនេះ នាងព្រមលើកទោសអោយសុត្តាក៏វាហួសពេលដែរ ព្រោះនាងបានភ្ជាប់ពាក្យនឹងដារីតរួចទៅហើយ។


បទចំរៀងដ៏ពិរោះរណ្ដំរបស់សុត្ថាធ្វើអោយស្រីត្រាណ
ត្រើយសែនអាលោះអាល័យដល់អនុស្សាវរីយ៍
ល្អៗ ទាំងឡាយដែលធ្លាប់មានជាមួយនឹងគ្នា។
បងសុត្ថា! បើបងស្រលាញ់អូន
ហេតុអ្វីបងបែរជាសេពគប់នឹង
មនុស្សមិនល្អ មកធ្វើបាបអូន។
បងដឹងថារូបអូនឈឺចាប់ប៉ុណ្ណា
បុរសដែលអូនស្រលាញ់
ពេញបេះដូងធ្វើរបៀបនេះ។
ពេលនេះអូនព្រមរៀបការ
នឹងគេហើយបង។ ទោះជា
អូនចង់បកក្រោយវិញ
ក៏មិនអាចទៅ
រួចដែរ។

តាំងពីគ្រានោះមក សុត្ថាករីចំរៀងឯក បានធ្វើឲ្យក្រុមហ៊ុនមានកត្តិយសល្បីល្បាញ និងទទួលបានប្រាក់ចំណូលកើនឡើងជាលំដាប់ ។ ទាំងនេះកាន់តែញ៉ាំងឲ្យថៅកែសានពេញចិត្តនឹងនាយជាខ្លាំង តែផ្ទុយទៅវិញអាលីនចេះតែហ្មួហ្មងនឹងគេទៅវិញ..។ ថ្ងៃនេះនាយបានច្បាប់អនុញ្ញាតិដើម្បីឈប់សំរាកមួយរយៈ ។




គ្រាន់តែឮដូច្នោះ អាលីនមិនសប្បាយចិត្ត ហើយទំលាក់ទឹកមុខស្រងូត...
អី...ទៅថ្ងៃណាទើប មកវិញ?
មិនទៀងទេ អាលីន ប្រហែលជា យូរបន្តិចហើយ។
ហេតុដូចម្ដេច ក៏សុត្ថាមិននាំម្ដាយ មកនៅភ្នំពេញហ្នឹង គេទៅ?
ពីមុនខ្ញុំនឹកគិតថាដូចនេះ ដែរ តែដល់ឥឡូវហាក់ដូចជា គ្មានសង្ឃឹមសោះអាលីន។


សុត្ថាមានមុខមាត់ប៉ុណ្ណេះទៅហើយ
ហេតុអ្វីក៏ពោលពាក្យយ៉ាងដូច្នេះ?
មុខមាត់អ្វីទៅ ! អាលីន!
ជីវិតអ្នកចំរៀងដូចខ្ញុំនេះ ហិចហើរមិនទៀងទាត់ឡើយ ជួនរាំង
ជួនភ្លៀង។ បើនិយាយទៅមិនខុសពីដំណក់ទឹកដែលកំពុងហូរធ្លាក់ចូល
សមុទ្រ រួចហូរទៅក្នុងទន្លេ ស្ទឹងដែលជាប្រភពដើមវិញជាមិនខាន។


ពាក្យសំដីបួរបាច់របស់កវីធ្វើឲ្យអាលីនគាំងនិយាយលែងរួច។
ណ្ហើយចុះអាលីន ខ្ញុំជូនរបស់នេះទុកជាអានុស្សាវរីយ៍ សូមមេត្តាទទួលយកផងចុះ!
តើជាអ្វីហ្នឹង សុត្ថា !
អាលីន បើក មើលទៅនឹងដឹង ជាពុំខាន...ខ្ញុំលាសិន ហើយអាលីន!...
អាលីនធ្លាប់ធ្មើងធ្មៃមិនចេះអង្វរ មិនចេះសារភាពនឹងអ្នកណាឡើយ ។ នាងរារែកមិនចង់ទទួលឡើយ តែពុំដឹងមូលហេតុអ្វី លើកនេះនាងប្រែជាចាប់កាន់របស់នោះទាំងមិនដឹងខ្លួន...។ ណាចង់ប្រែកែកវិញ តែវាហួសពេលទៅហើយ គឺសុត្ថាបានបររថយន្តចេញបាត់ទៅហើយ !


នឹកបងណាស់ នឹកបងណាស់ ម្ចាស់ស្នេហ៍អូនអើយ... ភ្លេចបងមិនបាន ឡើយ ម្ដេចឡើយបងមិនព្រមយល់ចិត្តអាណិតដល់នួនល្អង។ បងទៅមិន ហៅអូនទៅផង ទុកអោយនួនល្អងរង់ចាំបងម្នាក់ឯង...
ច្រៀងអីហ្នឹង?
បាទៗ អត់មានអីទេអ្នកនាង


ពេលបង់ទៅ... ពៅហើយ
ទឹកដល់អូនផង....
ឃើស ពូកែជៀមជាម
សម្បើមណាស់។ តិចអោយ
ប៉ាកាត់ប្រាក់ខែឥឡូវ...

ថ្ងៃបន្តិច រថយន្តសុត្ថាបានមកដល់បាត់ដំបង។ លើកនេះ គេពិតជាមិនចង់ធ្វើជាមនុស្សកំសាកដូចមុនឡើយ។ គេតាំងចិត្តរកជួបនឹងផល្លា ដើម្បីបញ្ជាក់នូវក្តីបរិសុទ្ធរបស់គេ។ គេមិនចង់ទុកអោយនាងបន្តការយល់ច្រលំបែបនេះតទៅទៀតទេ។ គិតហើយគេក៏ចូលទៅក្នុងផ្សារដើម្បីទិញផ្កាល្អៗ យកមកជូននាង...។




តែរំពេចនោះ នាយស្ទើរតែពុំជឿនឹងភ្នែក គឺខ្លួនប្រាណ មុខមាត់របស់ផល្លាបានមកឋិតនៅចំពោះ មុខគេទាំងស្រុង។
ផល្លា! ...
ផល្លា! បងមករកអូនហើយ ហេតុអ្វីក៏អូននៅស្ងៀមមិននិយាយ! តើអូន នៅតែស្អប់បងដូចមុនទៀតឬ? ផល្លាភ្លេចបង ហើយឬ? មិនសមទេ ព្រោះភ្នែកដ៏ស្រទន់ របស់អូនបញ្ជាក់ថាអូននៅចាំបង ច្បាស់ណាស់។
ពិតមែន...ផល្លាសំឡឹងសុត្ថាមិនដាក់ភ្នែកសោះ តែនាង នៅតែឈរស្ងៀម ដូចរូបចំលាក់គ្មាននិយាយស្តីមួយម៉ាត់សោះឡើយ ។


ទ្រាំពុំបាន សុត្ថាក៏បោះជំហានទៅរកនាង តែពុំដឹងយ៉ាងណា? នាងក៏បោះជំហានថយក្រោយបន្តិចម្តងៗ កាន់តែឆ្ងាយពីគេ...។
ទីបំផុតនាងក៏ឡើងរថយន្តជាមួយយុវជនម្នាក់ រួចក៏ចាកចេញទៅ។


គួរឲ្យអនិច្ចាណាស់ នេះជាលើកទីពីរហើយដែលកាន់តែ
ធ្វើឲ្យនាយអស់សង្ឃឹមរកទីបំផុតគ្មាន។ តើហេតុអ្វីក៏
នាងមានទឹកមុខស្រពោនសម្លឹងមករកគេដោយមិន
ចេញស្ដីទៅវិញ? តើក្នុងរយៈពេលដែលនាយឃ្លាតចេញ
ពីទីនេះ នាងមានអាថ៌កំបាំងដួងចិត្តអ្វីកើតឡើងទេឬ?
នាយក៏ប្រញាប់ត្រឡប់មករកម្ដាយខ្លួន។
កូនថា! កូនមកវិញហើយឬ? ម៉ែនឹកកូនណាស់។
ម៉ែ កូនមកយកម៉ែទៅនៅជាមួយហើយ។
មែនហ្អ៎... ម៉ែអរណាស់។




រួចហើយគេធ្វើដំណើរទៅវត្តជាមួយម្តាយ។ តាំងពីរឃ្លាតពីម្តាយមកគេ មានសេចក្តីនឹករលឹកម្តាយណាស់ តែអារម្មណ៍មួយក៏ចេះតែនៅនឹកឃើញ ផល្លាមិនភ្លេចសោះ។



កំពុងតែវិលវល់ក្នុងក្តីអស់សង្ឃឹម រំពេចនោះស្រាប់តែឃើញអាហួចចុះពីវិហារដើរតំរង់មក ។ នាងញញឹមដោយក្តីនឹករលឹក ។ នាងបានសួរសុខទុក្ខសុត្ថា ហើយក៏បានរៀបរាប់ពីរឿងផល្លាដែលដារីតចូលស្តីដណ្តឹង និងត្រូវរៀបការនាពេលឆាប់ៗនេះ។ ដល់ត្រឹមនេះ សុត្ថាទ្រាំស្តាប់ពុំបានក៏ពោលឡើងថា :



សុត្ថាអស់សង្ឃឹមនឹងសេចក្តីស្នេហាដែលគេមានចំពោះផល្លា។ សុត្ថាដេកគង់ថ្ងាសគិតតែម្នាក់ឯង តើរឿងរ៉ាវដែលកើតឡើងកន្លងមកនេះ ជាកំហុសរបស់នរណា។ ផល្លាមិនដែលស្តាប់ការបកស្រាយរបស់នាយម្តងណាសោះ។



សុត្ថាសំរេចចិត្តនាំម្តាយរបស់គេមកទីក្រុងភ្នំពេញ។ ត្រលប់មកពីបាត់ដំបង ភ្លាម សុត្ថាប្រញិបប្រញាប់ត្រលប់ទៅធ្វើការវិញភ្លាម។ គ្រាន់តែដឹងថា សុត្ថាត្រលប់មកវិញ អាលីនមិនបង្អង់យូរក៏ប្រញាប់មកជួបនឹងសុត្ថាភ្លាម។






សុត្ថាស្ទុះទៅយកកន្ត្រកផ្លែក្រូចពីក្នុងឡានអោយអាលីន។
នេះនែ ផ្លែក្រូច។
ផ្លែក្រូចច្រើនណាស់ខ្ញុំយកមិនកើតទេ។
អូហ៍ មែនចាំខ្ញុំអោយពូប្រិមដឹកដល់ផ្ទះអោយអាលីន។
–បងសុត្ថាមានរឿងអីបានជាមុខស្រពោនម្លេះ?
–ខ្ញុំពិបាកចិត្តណាស់អាលីន ព្រោះនារីម្នាក់ដែលខ្ញុំស្រលាញ់នោះ ឥឡូវនាងត្រូវឃ្លាតឆ្ងាយពីខ្ញុំហើយ...
–សុត្ថា បងថាម៉េច? អាលីន នឹកស្តាយចិត្ត គំនិតដែលលួចស្រលាញ់សុត្ថា តែអ្នកកំលោះបែរជាមានម្ចាស់បេះដូងរួចទៅហើយ!

ប៉ុន្មានថ្ងៃក្រោយមក សុត្ថាបានថតចំរៀងថ្មីមួយបទក្រោមចំណងជើងថា "រំដួលដងស្ទឹងសង្កែ"។ បទថ្មីនេះធ្វើអោយសុត្ថាល្បីរហូតដល់គេអញ្ជើញអោយឡើងទូរទស្សន៍សម្ភាសម្តងទៀត។




នៅឯបាត់ដំបងឯនេះវិញ ផល្លាបានមើលការសម្ភាសរបស់សុត្ថា។ នាងនឹកឃើញអនុស្សាវរីយ៍របស់នាង និងសុត្ថាធ្វើអោយទឹកភ្នែករបស់នាងស្រក់ចុះដោយមិនដឹងខ្លួន។
សុត្ថា បើបងស្រលាញ់អូន ហេតុអ្វីបងធ្វើបាបចិត្តរបស់អូនយ៉ាំងនេះ។


ថ្ងៃនេះផល្លាទៅផ្ទះដារីត។ ស្រាប់តែផល្លាបែរជាឃើញដារីតកំពុងនិយាយជាមួយនាយដេត និងនាយសាន់។
ពួកយើងបានយកទំនិញទាំងនេះមកដល់ចាត់ដំបងដោយជោគជ័យក៏ដោយសារតែពួកយើងបានបន្លំដាក់វានៅក្នុងបាវអង្ករ ទើបប៉ូលីសមិនសូវចាប់អារម្មណ៍ពិនិត្យ។
ខ្ញុំបានយកទំនិញទាំងអស់ទៅទុកនៅក្នុងឃ្លាំងរួចរាល់ហើយ។
ដឹកទៅ! ការងារនេះបានសំរេចក៏ដោយសារតែពួកយើងទាំងអស់គ្នាឆ្លាតជាងប៉ូលីសដែរ។


ពេលនេះផល្លាយល់ហើយ។ ការពិតគឺជាជាវីតទេ ដែលបានប្រើអោយ
អាដេត និងអាសាន់ធ្វើបាបនាងនិងសុគ្គា។
ពួកយើងលើកនេះ
ច្បាស់ជាចំណេញបានច្រើនមិនខានទេ?
ហាសហា...លើកកែវឡើង!!!!!
សុគ្គា អូនយល់ច្រលំលើ
បងហើយ។ សុំទោស អូនខុសហើយបង។


បន្តិចក្រោយមក ប៉ូលិសក៏បានមកដល់។ ប៉ូលិសចូលសំរុកទៅចាប់ដារីត
ដេត និងសាន់។ ដារីតដកកាំភ្លើងភ្ជង់ទៅប៉ូលិសវិញ តែប៉ូលិសដៃរហ័ស
បានបាញ់ដារីត ហើយបានចាប់ដារីត និងបក្សពួកគេពីរនាក់ទៀត។


ប៉ូលីសបានចាប់ដារីត ដេត និងសាន់ ដាក់ខ្នោះ នៅទីងមុខផល្ហា។
ពួកយើងបានតាមដានពួកឯងយូរហើយ។ ពួកឯងរកស៊ីជួញដូរគ្រឿងញៀន ស្មានតែពួកយើងភ្លើមិនដឹងថានៅក្នុងអង្កររបស់ពួកឯងជាគ្រឿងញៀនហ៊្ន។ យើងគ្រាន់តែចង់តាមដានកូនចៅដើម្បីចាប់មេធំដារីតឯងនេះប៉ុណ្ណោះ។ ភស្តុតាងគ្រប់គ្រាន់ ពួកឯងត្រូវតែដេកគុកហើយពេលនេះ។


នៅឯភ្នំពេញ សុត្ថាបានអានកាសែតឃើញ
ព័ត៌មានពីដារីត។ សុត្ថាដឹងថាមង្គលការ
របស់ផល្លាត្រូវបានរំសាយចោល។ គេដូច
ជាសប្បាយចិត្តណាស់ ក៏សុំច្បាប់ថៅកែមក
រកផល្លានៅបាត់ដំបង។ សុត្ថាមកដល់ផ្ទះ
ឃើញផល្លាកំពុងអង្គុយស្តាប់បទចំរៀង
"រំដួលដងស្ទឹងសង្កែ"។
ផល្លា ការពិតអូននៅ
ទឹកបងដែរមែនទេ?


សុត្ថាដើរចូលមករកផល្លា។
បងសុត្ថា
ផល្លា បងនៅទីនេះហើយ
បងបាន អានកាសែត ដឹងអស់ហើយ។ ពេលនេះគ្មាន នរណាមក បំបែកយើង ទៀតទេ។
គឺអូន សុំទោសផង ដែលយល់ច្រឡំ លើរូបបង។ បងមិនខឹងនឹង អូនទេហ្ន៎?


អឺ...
បងខឹងនឹងអូនម្ដេចកើត បើបេះដូងមានតែរូបអូនមួយនោះ។ ពេលនេះបងមានការងារធ្វើហើយ តើអូនព្រមទទួលស្នេហាពីបងទេ?
"អឺ" ... បានន័យថាយល់ព្រមហើយណ៎ា។

នៅទីបំផុត  ស្នេហារបស់សុគ្គាក៏បានដូចបំណង។  នេះគឺដូចជាពាក្យចាស់លោកថា "កុលាបតែងមានបន្លា ស្នេហាតែងមានឧបសគ្គ"។



# អំពីវិចិត្រករ



លោក ឯម សត្យា បានសរសេរសៀវភៅមួយក្បាលហើយ  ប៉ុន្តែថ្ងៃណាមួយអ្នកផ្សេងទៀតប្រហែលនឹងសរសេរសៀវភៅមួយក្បាលអំពីការងារ និងរឿងផ្សេងៗជាច្រើនរបស់គាត់វិញ។ អត្ថបទខាងក្រោមនេះរៀបរាប់ដោយសង្ខេបអំពីការងារសិល្បៈរបស់លោក  ឯម  សត្យា ដែលមានលក្ខណៈច្រើនបែបផែន។

គាត់បានកើតនៅភូមិស្វាយព្រៃ ខេត្តតាកែវ ឆ្នាំ១៩៥៧។ ក្នុងចំណោមកូនប្រាំនាក់ គាត់គឺជាកូនទីបួន  ហើយគាត់បានធំដឹងក្តីឡើងនៅស្រុកទន្លេបាទី។ លោក ឯម សត្យា មានការចាប់អារម្មណ៍ទៅលើផ្នែកសិល្បៈតាំងពីតូចមកម្ល៉េះ។ គាត់នៅចាំថា កាលគាត់នៅពីក្មេងគេបាននាំគាត់ទៅមើលពិព័រណ៍សិល្បៈ។ ហើយពេលគាត់មានវ័យជំទង់ គាត់ចូលចិតអានសៀវភៅរឿងរូបភាពជាភាសាខ្មែរ  និងភាសាបារាំង ហើយនឹងគូរគំនូរជាញឹកញាប់ថែមទៀតផង ។



***រូបគំនូរដោយវិចិត្រករ ឯម សត្យា***

ឪពុករបស់គាត់ធ្លាប់ធ្វើការនៅក្រសួង




*ព្រះគុណថ្លៃថ្លា_គំរបសៀវភៅរឿង ប្រលោមលោកនៅឆ្នាំ១៩៩៧*

អប់រំ។ លោក ឯម សត្យា បានរស់នៅក្នុងមជ្ឈដ្ឋានមួយដែលបានជំរុញអោយគាត់ឈានជើងចូលទៅក្នុងវិស័យសិល្បៈ។

គាត់បានព្យាយាមរៀនអោយបានបរិញ្ញាប័ត្រពីសកលវិទ្យាល័យវិចិត្រសិល្បៈនៅអំឡុងឆ្នាំ ១៩៧៤ និង ឆ្នាំ១៩៧៥ ។ នៅពេលដែលទីក្រុងភ្នំពេញដួលរលំ គេបានជំលៀសគាត់ទៅស្រុកកំណើតវិញ ហើយគេបានបញ្ជាអោយគាត់ចូលរួមក្នុងការងារសហករ។ ទេពកោសល្យរបស់គាត់បានជួយគាត់អោយរស់រានឆ្លងផុតពីពេលវេលាដ៏លំបាកនេះបាន។ កម្មាភិបាលខ្មែរក្រហម បានអោយគាត់គូរគំនូរមុខមនុស្សជាថ្នូរនឹងចំណីអាហារ។

ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម លោក ឯម សត្យា បានសហការជាមួយមិត្តភ័ក្តិម្នាក់នៅឆ្នាំ ១៩៧៩ ដើម្បីបង្កើតក្រុមល្ខោនមួយ ដែលក្រុមនេះសំដែងអំពីរឿងរ៉ាវប្រវត្តិសាស្ត្រដែលទើបតែកើតឡើង។ ក្រសួងវប្បធម៌បានលើកទឹកចិត្តទៅដល់ការខិតខំប្រឹងប្រែងរបស់ក្រុមគាត់។ មិនយូរប៉ុន្មានគាត់ក៏បានរកឃើញការងារជាប់លាប់មួយនៅក្រសួងអបរំ។ គាត់បានគូររូបមួយចំនួនសំរាប់សៀវភៅសិក្សាផ្សេងៗ។ ពេលនោះគាត់មានការសប្បាយចិត្តដោយបានធ្វើការជាមួយសិល្បៈករមួយចំនួនដូចជាលោក អ៊ុត វឿន លោក ហ៊ុល សាផុន និងលោក ចាន់ ត្រា។ ការទទួលកាងារជាប់លាប់នេះបានធ្វើអោយគាត់មានលទ្ធភាពរៀបការនៅឆ្នាំ ១៩៨៤។

នៅចុងទសវត្សរ៍ទី៨០ សៀវភៅរឿងរូបភាពបានកើតមានឡើងវិញជាទំរង់សិល្បៈមួយបែប។ នៅពេលទំទេរ លោក ឯម សត្យា បានគូរគំនូររឿងបុរាណជាច្រើនដែលត្រូវបានបោះពុម្ពឡើងវិញនាប៉ុន្មានទសវត្សរ៍ក្រោយមក។ រឿងទាំងនោះមានដូចជា សុណ្ណសាម សព្វសិទ្ធ និងរឿងមនោសច្ចេតនាជាច្រើន។

គាត់បានចាប់ផ្តើមសរសេររឿងបុប្ផបាត់ដំបងនៅឆ្នាំ ១៩៩០ ជាការកំសាន្តដោយលាយបញ្ចូលសិល្បៈខ្មែរបុរាណជាមួយនឹងឥទ្ធិពលខ្សែភាពយន្តឥណ្ឌា។ លោក ឯម សត្យា ក៏បានធ្វើការសាកល្បងរចនាបែបថ្មីនៅក្នុងសៀវភៅនេះ។ នៅសម័យនោះ មនុស្សទាំងអស់ពេញនិយមមើលទូរទស្សន៍ និងខារ៉ាអូខេ។ ពេលដែល លោក ឯម សត្យា បានបង្ហាញសៀវភៅរបស់គាត់ទៅអ្នកលក់នៅតាមផ្សារ ពួកគាត់មិនសូវចាប់អារម្មណ៍ប៉ុន្មានទេ។ ទោះបីជាគាត់បានសរសេររឿងបុប្ផបាត់ដំបងស្ទើតែចប់ក៏ដោយ ក៏គាត់បង្ខំចិត្តឈប់ដើម្បីផ្តោតទៅលើការងារគំនូរផ្សេងៗឯទៀតវិញ។



*រាត្រីខ្មោចយកព្រលឹង_គំរបសៀវភៅរឿងប្រលោមលោក*

បន្ទាប់ពីឈប់ធ្វើការនៅក្រសួង គាត់បានធ្វើជាអ្នកគំនូររូបថ្លុកដ៏មានប្រជាប្រិយភាពអោយកាសែតរស្មីកម្ពុជា ហើយជាមួយគ្នានោះ គាត់ទទួលបានកំរៃខ្លះទៀតពីការងារគំនូររបស់គាត់។ រូបថ្លុកមួយចំនួនរបស់គាត់ត្រូវបានបោះពុម្ពផ្សាយឡើងវិញនៅក្នុងអត្ថបទប្រែសំរួលរបស់កាសែតកាំបូសរ័ ។ គំនូរប្រេងរបស់គាត់ត្រូវបានបោះពុម្ពលើក្របមុខសៀវភៅ




*សម្រែកព្រៃឈើ_វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ*

ប្រលោមលោកខ្មែរជាច្រើន។ មិត្តអ្នកអាន ទាំងខ្មែរ ទាំងបរទេស បានឃើញស្នាដៃរបស់លោក ឯម សត្យា នៅអង្គការ រិដបានណា អង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ទស្សនាវដ្តីមុំ និង ម៉ាប់ និងការបោះពុម្ពផ្សាយរបស់រដ្ឋាភិបាលជាច្រើនទៀត។

នៅឆ្នាំ២០០០ គាត់មានជំងឺដាច់សរសៃឈាមដែលធ្វើអោយគាត់ស្លាប់មួយចំហៀងខ្លួនខាងស្តាំ ហើយធ្វើអោយដៃស្តាំរបស់គាត់មិនអាចគូរបាន។ លោក ឯម សត្យា បានហាត់គូរឡើងវិញបន្តិចម្តងៗ ដោយគូររូបដែលគាត់ធ្លាប់បានគូរជាច្រើនដងកន្លងមក ដូចជារូបអង្គរវត្តជាដើម។ គាត់និយាយថា "ខ្ញុំមានអារម្មណ៍ថា ខ្ញុំជាអ្នកគំនូរដែលកំពុងតែចាប់ផ្តើមរៀនគូរតាំងពីដំបូង ហើយខ្ញុំត្រូវគូរម្តងហើយម្តងទៀត។" បន្តិចម្តងៗ គាត់បានទទួលនូវការងារជាប់លាប់ឡើងវិញ។ អ្នកដំបូងដែលជួលគាត់ឡើងវិញ គឺមានអ្នកនិពន្ធ លោកស្រី ប៉ាល់ វណ្ណារីរក្ស។ ឯអ្នកបន្តបន្ទាប់ទៀតមានអង្គការបន្ទប់សំរាប់អាន ***( Room to Read )*** រោងពុម្ពដំរីស រោងពុម្ពបន្ទាយស្រី និងរោងពុម្ពផ្សេងៗ ជាច្រើនទៀតផង។

នៅក្នុងឆ្នាំ ២០០៤ គេបានស្នើរសុំអោយលោក ឯម សត្យា ធ្វើជាអ្នកតំណាងអោយប្រទេសកម្ពុជា ចូលរួមពិព័រណ៍ស្នាដៃគំនូរថ្នាក់ស្តីពីបរិស្ថានដែលធ្វើឡើងនៅប្រទេសជប៉ុន ហើយនៅឆ្នាំ២០០៧ ពិព័រណ៍នេះក៏ត្រូវបានតាំងបង្ហាញនៅ



*ថ្ងៃណាអូនអាណិតបង-គំនូរសំរាប់កាសែត*



*សព្វសិទ្ធ -សៀវភៅរឿងរូបភាព*

ប្រទេសកម្ពុជាផងដែរ។

នៅឆ្នាំ ២០០៦-២០០៧ គាត់បានចាប់ផ្ដើមសរសេរបញ្ចប់រឿងបុប្ផាចាត់ដំបងក្រោយពីបានផ្អាកសរសេរជិតពីរទស្សន៍មក។ ទំព័រចុងក្រោយនៃរឿងនេះមានសភាពកាន់តែស្អាតដូចពិត។ ហើយកាន់តែរស់រវើកជាងមុន។ ជំនាញរបស់គាត់ក្នុងការគូររឿងបុរាណបានធ្វើអោយគាត់គូររូបមួយចំនួនអោយវិទ្យាស្ថានពុទ្ធ




*រឿងនិទានសំរាប់កុមារ_ជ័រីសរ*

សាសនបណ្ឌិត្យផ្នែកប្រពៃណី និងទំនៀមទំលាប់។ គាត់បានបោះពុម្ពសៀវភៅរឿងនិទានរូបភាពសំរាប់កុមារ។ នៅថ្ងៃអនាគត គួរតែមានការសរសេរពីប្រវត្តិស្នាដៃរបស់លោក ឯម សត្យា ។ តែសំរាប់ពេលនេះ យើងសង្ឃឹមថាអត្ថបទខ្លីខាងលើនេះនឹងជួយនាំអោយមានការចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗ  ពីសិល្បៈករ និងអ្នកស្រាវជ្រាវទៅលើសិល្បៈទស្សនីយភាពបែបទំនើបនៅប្រទេសកម្ពុជា។

# សៀវភៅរឿងឆាករូបភាព
# សំរាប់ទាំងអស់គ្នា




**អង្គការ សៀវភៅយើង**

ផ្ទះលេខ៦៧E១ ផ្លូវលេខ១៧៨ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ
ភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៩៨៨
ទូរស័ព្ទ : 012 526 840 / 023 223 242

info@siewphewyeung.org.kh
http://www. siewphewyeung.org.kh



សុត្ថាគឺជាយុវជនម្នាក់រស់នៅខេត្តបាត់ដំបង ដែលកើតចេញពីត្រកូលសាមញ្ញ។ គាត់មានទេពកោសល្យ និងមានឧត្តមគតិខ្ពស់។ អ្វីដែលសំខាន់នោះ គឺគាត់សង្ឃឹមនឹងយកជ័យជំនះលើសេចក្តីស្រឡាញ់ចំពោះមិត្តរបស់ខ្លួន ឈ្មោះផល្លាដែលជាកូនស្រីរបស់អ្នកជំនួញដ៏ស្តុកស្តម្ភម្នាក់។

ដោយសារតែសុត្ថាបានជួយបង្ហាត់បង្រៀនមេរៀនដល់ផល្លា ទើបធ្វើអោយផល្លា អោយតំលៃយ៉ាងជ្រាលជ្រៅទៅលើពេលវេលារបស់នាងជាមួយនឹងសុត្ថា។

ការចាប់ជីវិតនៅតាមផ្លូវបានទំលាក់កំហុសអោយសុត្ថា ដែលធ្វើអោយសុត្ថាចាកចេញពីភូមិកំណើតហើយប្តូរឈ្មោះ ដើរត្រាច់ចរដោយគ្មានទិសដៅ ហើយនឹងបន្សល់នូវភាពយល់ច្រលំក្នុងក្រសែភ្នែកផល្លា។ ក្នុងខណៈនោះ ដារីតគ្រោងនឹងរៀបការជាមួយនឹងផល្លា ដែលការរៀបចំនេះហាក់បីដូចជាការផ្គូផ្គងដ៏ល្អឥតខ្ចោះ...



តើសុត្ថាមានភាពក្លាហានក្នុងការស្រមើស្រមៃពីអនាគតជាមួយនឹងស្នេហ៍ដ៏ក្មេងខ្ចីរបស់ខ្លួនដែលឬទេ? ចំលើយគឺមានតែនៅក្នុងជោគវាសនា និងក្នុងបេះដូងរបស់ផល្លាតែមួយគត់។

លសខអ_១៣ : ៩៧៨_៩៩៥០_៨៥៣_៤_៦

ISBN-13: 978-9950-853-4-6

9789995085346

តំលៃ ៤០០០ រៀល/១ ដុល្លា

បោះពុម្ពលើកទី ២ ចំនួន ២០០០ ច្បាប់